# សេរីភាពខាងសមាគម-( ឆ្នាំទី៦៖ ខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ )

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន( "គម្រោង" )គឺជាគម្រោងដែលពិនិត្យជាប្រព័ន្ធនូវលទ្ធភាពរបស់ពលរដ្ឋកម្ពុជាក្នុងការអនុវត្តសិទ្ធិសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ ព័ត៌មាននេះបង្ហាញពីចំណុចគន្លឹះទាក់ទងនឹងសេរីភាពខាងសមាគមដែលបានមកពីរបាយការណ៍ប្រចាំឆ្នាំទី៦ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាន។ ក្នុងឆ្នាំ២០២១ គម្រោងបានកត់ត្រា ការរឹតត្បិតចំនួន២០០ ករណីលើសេរីភាពខាងសមាគម ដែលក្នុងចំណោមនោះមាន ១៥៤ ករណីជាការរំលោភបំពាន។

## មានត្រឹមតែ ២៩% នៃចំនួនសាធារណជនដែលរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយដែលជាធាតុសំខាន់មួយនៃសេរីភាពខាងសមាគម




*របកគំហើញនេះបង្ហាញពីបរិយាកាសបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាដែលមិនអំណោយផលដល់ទិដ្ឋភាពនយោបាយ នាំឱ្យមានការបារម្ភពីការរឹតត្បិតនានាជុំវិញការបោះឆ្នោតឆ្នាំ២០២២ និងឆ្នាំ២០២៣។*

## ការយល់ដឹងរបស់សាធារណជនអំពីច្បាប់ពាក់ព័ន្ធនឹងសេរីភាពខាងសមាគមមានភាពប្រសើរ

*ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយត្រឹមត្រូវ.....*




សាធារណជនភាគច្រើនបានដឹងថាអង្គការមិនមែនរដ្ឋាភិបាលត្រូវតែចុះបញ្ជីនៅក្រសួងមហាផ្ទៃដើម្បីអាចប្រតិបត្តិការដោយស្របច្បាប់បាន ប៉ុន្តែសាធារណជនតិចតួចប៉ុណ្ណោះដែលដឹងថាតម្រូវការបែបនេះក៏អនុវត្តចំពោះក្រុមសន្សំដែរ។

*កំណត់សម្គាល់៖ លក្ខខណ្ឌចុះបញ្ជីដែលកំណត់មកលើសមាគមមិនស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ។*

## ៦៥% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពបានរាយការណ៍ថាបានបង្កើនសុវត្ថិភាពឬបង្ការពីការឃ្លាំមើលពីរដ្ឋាភិបាល




## ការរឹតត្បិតសេរីភាពខាងសមាគមជារឿយៗត្រូវបានកំណត់មុខសញ្ញាលើអ្នកមានទស្សនៈនយោបាយផ្ទុយ

**២៨២** នាក់ដែលសេរីភាពខាងសមាគមត្រូវបានរឹតត្បិត

**១០១** នាក់ជាសកម្មជននយោបាយឬអ្នកនយោបាយ

**៩៤** នាក់ជាសកម្មជននយោបាយ ឬអ្នកនយោបាយ ជាប់ពាក់ព័ន្ធនឹងអតីតគណបក្សសង្គ្រោះជាតិ

## ការតាមឃ្លាំមើលជាញឹកញាប់លើសកម្មភាពរបស់សមាគមដោយរដ្ឋាភិបាលបង្ហាញពីការមិនទុកចិត្តមកលើសង្គមស៊ីវិល




*ភាគរយនៃហេតុការណ៍ពាក់ព័ន្ធសេរីភាពខាងសមាគមដែលរដ្ឋាភិបាលតាមដានឃ្លាំមើលហួសហេតុ*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

សមាគមអាដហុក ADHOC

SOLIDARITY CENTER

ICNL INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

CC BY NC SA

ខែមេសា ឆ្នាំ២០២២